ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈទន្តពេទ្យកម្ពុជា

# គោលការណ៍ណែនាំ

# ស្តីពី

# ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ថ្ងៃពុធ ១៤រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៩

**សេចក្តីផ្តើម**

អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាល គណៈទន្តពេទ្យកម្ពុជា មានតួនាទីជានិយតករក្នុងការបង្កើតលក្ខខណ្ឌតម្រូវនានា សម្រាប់អ្នកវិជ្ជាជីវៈទន្តសាស្ត្រ និងអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ក្នុងការផ្តល់សេវាប្រកបដោយគុណភាព សុវត្ថិភាព។

**តួនាទីទាំងនេះរួមមាន៖**

- ចុះបញ្ជិកាអ្នកវិជ្ជាជីវៈទន្តសាស្ត្រ
- ចេញអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ចំពោះអ្នកវិជ្ជាជីវៈទន្តសាស្ត្រ ដែលបានចុះបញ្ជិការួចហើយ
- ធានាថាអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ដែលបានចុះបញ្ជិកា និងមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈទាំងអស់ បំពេញតាមលក្ខខណ្ឌតម្រូវអប្បបរមា ដើម្បីបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈរបស់ខ្លួនយ៉ាងទៀងទាត់
- គ្រប់គ្រងការប្រកបវិជ្ជាជីវៈរបស់អ្នកវិជ្ជាជីវៈទន្តសាស្ត្រ និងអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ តាមរយៈការបង្កើតក្រម សេចក្តីសម្រេច និយាម គោលការណ៍ណែនាំ និងបទដ្ឋាននានា របស់គណៈទន្តពេទ្យកម្ពុជា សម្រាប់ការប្រកបវិជ្ជាជីវៈសុខាភិបាល
- ស៊ើបអង្កេតបណ្តឹង ដែលពាក់ព័ន្ធនឹងសម្បទា សមត្ថភាព និងការប្រព្រឹត្ត របស់អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ដើម្បីអាចដាក់ទណ្ឌកម្មខាងវិន័យ ឬ/និងគាំពារ ឱ្យបានសមស្រប ។

គោលការណ៍ណែនាំទាំងនេះ បំពេញបន្ថែមនូវនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងផ្តល់ព័ត៌មានបន្ថែមអំពីលក្ខខណ្ឌតម្រូវអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់គណៈទន្តពេទ្យកម្ពុជា សម្រាប់រយៈពេល ៣(បី)ឆ្នាំ។

គោលការណ៍ណែនាំនេះពន្យល់ប្រាប់ថា តើអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ អាចបំពេញតាមលក្ខខណ្ឌតម្រូវរបៀបណា ដើម្បីធានាថា ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ពាក់ព័ន្ធនឹងវិជ្ជាជីវៈទន្តសាស្ត្រ ព្រមទាំងបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់ពួកគេក្នុងការផ្តល់សេវាសុខាភិបាល ដល់អ្នកជំងឺ ឬអតិថិជន ស្របតាមក្រមសីលធម៌ លិខិតបទដ្ឋានគតិយុត្តនានា ប្រកបដោយគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព។

## ១. ការអនុវត្តន៍គោលការណ៍ណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបន្ត

គោលការណ៍ណែនាំទាំងនេះប្រើសម្រាប់ទន្តពេទ្យទាំងអស់ ដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈទន្តសាស្ត្រ។

## ២. ភាតព្វកិច្ចរបស់អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ

អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ត្រូវបំពេញសកម្មភាពឱ្យស្របតាមនិយាមនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត របស់គណៈទន្តពេទ្យកម្ពុជា រយៈពេល ៣(បី)ឆ្នាំ នៃវដ្តនីមួយៗ។ សកម្មភាពនេះ ត្រូវតែពាក់ព័ន្ធនឹងវិជ្ជាជីវៈទន្តសាស្ត្រ តម្រូវការក្នុងការសិក្សារបស់បុគ្គលម្នាក់ៗ និងត្រូវតែបំពេញឱ្យបានគ្រប់មុនពេលបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ។

## ៣. វដ្តពិន្ទុ និងចំនួនម៉ោងរៀនសកម្ម នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត

វដ្តនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តនីមួយៗ ចាប់ផ្តើមពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនីមួយៗ ត្រូវបានផ្តល់ដោយគណៈទន្តពេទ្យកម្ពុជា រហូតដល់កាលបរិច្ឆេទដែលអាជ្ញាបណ្ណអស់សុពលភាព ។

អ្នកប្រកវិជ្ជាជីវៈទន្តសាស្ត្រ ដែលជាជនបរទេស ត្រូវបំពេញពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តអប្បបរមា ២០(ម្ភៃ)ពិន្ទុ ក្នុងវដ្ត ១(មួយ)ឆ្នាំ ។

អ្នកប្រកវិជ្ជាជីវៈទន្តសាស្ត្រ ដែលជាជនជាតិខ្មែរ ត្រូវបំពេញពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៦០(ហុកសិប)ពិន្ទុ អំឡុងពេល ៣(បី)ឆ្នាំ។

សម្រាប់ឆ្នាំនីមួយៗនៃវដ្តការអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ដែលជាជនជាតិខ្មែរ ត្រូវបំពេញពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តអប្បបរមា ១០(ដប់) អតិប្បរិមា៣០(សាមសិប)ពិន្ទុរៀងរាល់ឆ្នាំ ។

១(មួយ)ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត គឺស្មើនឹង១ម៉ោងនៃការរៀនសកម្ម មានន័យថា៦០(ហុកសិប)ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្តក្នុងរយៈពេល ៣(បី)ឆ្នាំ។ ពិន្ទុសរុបលើសក្នុងវដ្តមួយ មិនអាចផ្ទេរទៅវដ្តបន្ទាប់បានទេ។

**៤. ប្រភេទសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការផ្តល់ពិន្ទុការអភិវឌ្ឍវិជ្ជាជីវៈបន្ត**

គណៈទន្តពេទ្យកម្ពុជា តម្រូវឱ្យអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រម្នាក់ៗ ចូលរួមសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តផ្សេងៗរួមមាន៖

(១) ពាក់ព័ន្ធទៅនឹងវិជ្ជាជីវៈបច្ចុប្បន្ន និងអនាគត

(២)ឆ្លើយតបទៅនឹងតម្រូវការសិក្សា ដែលបានកំណត់។

សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងនេះត្រូវបានគេរំពឹងថា នឹងពង្រីកសមត្ថភាពវិជ្ជាជីវៈដែលមានស្រាប់ និងមិនមែនជាផ្នែកនៃតម្រូវការការងារប្រចាំថ្ងៃឡើយ ។

សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាច្រើន ដែលត្រូវបានទទួលស្គាល់ដោយគណៈវិជ្ជាជីវៈទន្តពេទ្យកម្ពុជា ដូចមាននៅក្នុងតារាងខាងក្រោមដើម្បីជាមគ្គុទ្ទេសក៍។ ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តនីមួយៗគឺ អាស្រ័យលើចំនួនម៉ោងជាក់ស្តែងដែលអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រចូលរួមយ៉ាងសកម្ម នៅក្នុងសកម្មភាពសិក្សា។ ពេលវេលាចំណាយសម្រាប់សកម្មភាពកម្មវិធីដូចជា ការចុះឈ្មោះ ការសម្រាកពិសាអាហារសម្រន់ សុន្ទរកថា និងកម្មវិធីផ្សេងៗ មិនត្រូវបានទទួលស្គាល់ថាជាការរៀនសកម្ម និងមិនអាចចាត់ចូលជាពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តបានទេ។ ឧទាហរណ៍៖ សិក្ខាសាលាដែលមានរយៈពេល ១(មួយ)ថ្ងៃ ឬ៨(ប្រាំបី)ម៉ោង ដែលក្នុងនោះរាប់បញ្ចូលទាំងម៉ោងនៃការពិសាអាហារ សម្រាកអាហារសម្រន់ និងសម្រាប់សុន្ទរកថា នោះបានន័យថាសកម្មភាពរៀនសកម្មមានតែ៥(ប្រាំ)ម៉ោងប៉ុណ្ណោះ បានន័យថា ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសរុបសម្រាប់សិក្ខាសាលានេះ គឺ ៥(ប្រាំ)ពិន្ទុ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមាននៅក្នុងតារាងខាងក្រោម រួមបញ្ចូលចំនួនពិន្ទុអតិបរមា នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលត្រូវបានផ្តល់ ដោយមិនគិតពីចំនួនម៉ោងសរុបនៃការរៀនសូត្រសកម្ម ។
ឧទាហរណ៍៖ វគ្គបណ្តុះបណ្តាលរយៈពេល ៤(បួន)ថ្ងៃ ដែលមានការរៀនសូត្រសកម្មសរុបអាចដល់២៤(ម្ភៃបួន)ម៉ោងស្មើនឹង២៤(ម្ភៃបួន)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។ ទោះយ៉ាងនេះក្តី ពិន្ទុអតិបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់វគ្គនេះទទួលបានត្រឹមតែ១៥(ដប់ប្រាំ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

ការបណ្តុះបណ្តាល ឬសិក្ខាសាលាដែលមានរយៈពេលពី ១(មួយ)ថ្ងៃ ទៅ ≤ ២សប្តាហ៍ គឺទទួលបាន ១៥(ដប់ប្រាំ)ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

នៅពេលបញ្ចប់ការសិក្សាដោយជោគជ័យ មានការវាយតម្លៃចំណេះដឹង (Post Test ) ដែលជាផ្នែកនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ជាប់ជាផ្លូវការ ដោយមានភស្តុតាងបង្ហាញ នោះសិក្ខាកាមអាចទទួលបាន ២(ពីរ)ពិន្ទុ បន្ថែមទៀតលើពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសរុប ។

***សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការបែងចែកពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត***

| # | សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត | ចំនួនពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត [១(មួយ)ពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត=១(មួយ) ម៉ោង នៃការរៀនសកម្ម] | ចំនួនពិន្ទុ នៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត អតិបរមា |
|---|---|---|---|

| | | | |
|---|---|---|---|
| ១ | ការពិភាក្សាករណីសិក្សាជាក្រុម/ ចូលរួមការប្រជុំបច្ចេកទេស(ក្លូឡូក) | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង |
| ២ | ការសិក្សាដោយខ្លួនឯង* (អានអត្ថបទទិនានុប្បវត្តិ នៅក្នុងទិនានុប្បវត្តិល្បីៗ ទាក់ទងនឹងសុខភាព ឬការបោះពុម្ពផ្សាយតាមអ៊ីនធឺណេតទាក់ទងនឹងសុខភាពឬ វេបីណា (Webinars) ឬ វីដេអូទាក់ទងនឹងសុខភាព)<br>* ត្រូវការភស្តុតាងជាលាយលក្ខណ៍អក្សរ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង រហូតដល់អតិបរមា ១០(ដប់)ពិន្ទុ |
| ៣ | សិក្ខាសាលាបណ្តុះបណ្តាល ដែលមានរយៈពេល ១(មួយ)ថ្ងៃ - ២(ពីរ)សប្តាហ៍ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ១៥ (ដប់ប្រាំ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង រហូតដល់អតិបរមា ១៥(ដប់)ពិន្ទុ |
| ៤ | បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល >២(ពីរ)សប្តាហ៍ ទៅ ៣(បី)ខែ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ២៥ (ម្ភៃប្រាំ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង រហូតដល់អតិបរមា ២៥(ម្ភៃប្រាំ)ពិន្ទុ |
| ៥ | បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល >៣(បី)ខែ ទៅ ៦(ប្រាំមួយ)ខែ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ៣៥ (សាមសិបប្រាំ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង រហូតដល់អតិបរមា ៣៥(សាមសិបប្រាំ)ពិន្ទុ |
| ៦ | បានបញ្ចប់វគ្គខ្លីដែលមានរយៈពេល >៦(ប្រាំមួយ)ខែ ទៅ ១២(ដប់ពីរ)ខែ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗរហូតដល់អតិបរមា ៤៥ (សែសិបប្រាំ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង រហូតដល់អតិបរមា ៤៥(សែសិបប្រាំ)ពិន្ទុ |
| ៧ | ចូលរួមការអប់រំនៅកន្លែងធ្វើការ វគ្គសិក្សាក្នុងពេលបំពេញការងារ(In-service training) ឬកម្មវិធីអភិវឌ្ឍជំនាញ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់ម៉ោងរៀនសកម្មនីមួយៗ | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង |
| ៨ | ចូលរួមសន្និសីទក្នុងប្រទេសកម្ពុជា | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង |
| ៩ | ចូលរួមសន្និសីទ សន្និបាត មហាសន្និបាតក្រៅប្រទេស | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗ រហូតដល់អតិបរមា២០ (ម្ភៃ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង រហូតដល់អតិបរមា ២០(ម្ភៃ)ពិន្ទុ |
| ១០ | ស្រាវជ្រាវ រៀបចំ សម្រាប់ធ្វើបទបង្ហាញ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងស្រាវជ្រាវ | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង រហូតដល់អតិបរមា ១០(ដប់)ពិន្ទុ |

| | | | |
|---|---|---|---|
| | នៅម៉ោងបង្រៀន ឬបទបង្ហាញក្នុងសន្និសីទជាតិ ឬអន្តរជាតិ (ដែលមិនមែនជាផ្នែកនៃការបង្រៀនដូចធម្មតា) | រៀបចំ ដើម្បីធ្វើបទបង្ហាញ ហួតដល់អតិបរមា ១០(ដប់)ម៉ោង | |
| ១១ | ចូលរួមជាសមាជិកក្នុងក្រុមស្រាវជ្រាវ ឬការងារគម្រោងទាក់ទងនឹងសុខភាព | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហួតដល់អតិបរមា ១០(ដប់)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ១០(ដប់)ពិន្ទុ |
| ១២ | ចូលរួមជាសមាជិកក្នុងក្រុមក្នុងការ បង្កើតគោលនយោបាយ ពិធីសារ និងគោលការណ៍ណែនាំនានាទាក់ទងនឹងសុខភាព | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហួតដល់អតិបរមា ១០(ដប់)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ១០(ដប់)ពិន្ទុ |
| ១៣ | ស្រាវជ្រាវបន្ថែមនិងរៀបចំ ដើម្បីអភិវឌ្ឍតួនាទីជាគ្រូណែនាំតាមមន្ទីរពេទ្យ គ្រូណែនាំគ្រូបង្វឹកបុគ្គលិកឬនិស្សិត ហើយមានផែនការបណ្តុះបណ្តាលដែលមានឯកសារត្រឹមត្រូវ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហួតដល់អតិបរមា ១០(ដប់)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ១០(ដប់)ពិន្ទុ |
| ១៤ | ចូលរួមពិនិត្យនិងកែសម្រួលឯកសារអប់រំពាក់ព័ន្ធនឹងសុខាភិបាល អត្ថបទទិនានុប្បវត្តិ ជំពូកក្នុងសៀវភៅ ឬឯកសារសិក្សាស្រាវជ្រាវ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហួតដល់អតិបរមា ១៥(ដប់ប្រាំ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ១៥(ដប់ប្រាំ)ពិន្ទុ |
| ១៥ | ក្នុងនាមជាសហនិពន្ធ ចុះផ្សាយឯកសារ ឬរបាយការណ៍ ពាក់ព័ន្ធនឹងសុខាភិបាល | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហួតដល់អតិបរមា ១៥(ដប់ប្រាំ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ១៥(ដប់ប្រាំ)ពិន្ទុ |
| ១៦ | សរសេរអត្ថបទស្រាវជ្រាវ ជំពូកសៀវភៅ ឬរបាយការណ៍ក្នុងនាមជាអ្នកនិពន្ធទី១ ហើយបញ្ជូនដើម្បីចុះផ្សាយ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហួតដល់អតិបរមា ២០(ម្ភៃ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ២០(ម្ភៃ)ពិន្ទុ |
| ១៧ | ចុះផ្សាយឯកសារ ជំពូកសៀវភៅ ឬរបាយការណ៍ពាក់ព័ន្ធនឹងសុខាភិបាល ក្នុងនាមជាអ្នកនិពន្ធទី១ | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហួតដល់អតិបរមា ២០(ម្ភៃ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ២០(ម្ភៃ)ពិន្ទុ |
| ១៨ | ជាប្រធានដឹកនាំក្នុងការសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងសុខភាព | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហួតដល់អតិបរមា ២៥(ម្ភៃប្រាំ)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ២៥(ម្ភៃប្រាំ)ពិន្ទុ |
| ១៩ | ជាប្រធានសម្របសម្រួលក្នុងការធ្វើគម្រោងទាក់ទងនឹងសុខភាព | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្ម | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង ហួតដល់អតិបរមា ២៥(ម្ភៃប្រាំ)ពិន្ទុ |

| | | | |
|---|---|---|---|
| | | នីមួយៗហូតដល់អតិបរមា ២៥ (ម្ភៃប្រាំ)ម៉ោង | |
| ២០ | រៀនវគ្គក្រោយឧត្តមសិក្សាដែលពាក់ព័ន្ធនឹងជំនាញ នៅក្នុងប្រទេស ឬក្រៅប្រទេស ដែលទទួលបានគុណវុឌ្ឍិជាផ្លូវការ ដូចជា បរិញ្ញាបត្រ សញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ឬ បណ្ឌិត | ១(មួយ)ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់ម៉ោងរៀនសកម្មនីមួយៗហូតដល់អតិបរមា ៦០ (ហុកសិប)ម៉ោង | ពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តជាក់ស្តែង រហូតដល់អតិបរមា ៦០(ហុកសិប)ពិន្ទុ |

**ការផ្តល់សកម្មភាព និងពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត**

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត នឹងត្រូវអនុវត្តជាចម្បងតាមរយៈ៖

- ការសិក្សាជាមួយគ្រូ ឬអ្នកសម្របសម្រួលដោយផ្ទាល់ ឬការរៀនដោយខ្លួនឯង
- ការរៀន និងការបណ្តុះបណ្តាលតាមប្រព័ន្ធព័ត៌មានវិទ្យា(Online training)និងការសិក្សាជាក្រុម ដោយការធ្វើបទបង្ហាញតាមវីដេអូ

ចំពោះសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត តាមរយៈការបណ្តុះបណ្តាលតាមប្រព័ន្ធព័ត៌មានវិទ្យា(Online training) ចាំបាច់ត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីសកម្មភាព(វិញ្ញាបនបត្របញ្ចប់ការសិក្សា និងការវាយតម្លៃ)។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតាមរយៈការបណ្តុះបណ្តាលតាមប្រព័ន្ធព័ត៌មានវិទ្យា(Online training) ដែលជាលក្ខណៈអន្តរជាតិអាចត្រូវបានទទួលស្គាល់ដោយគណៈទន្តពេទ្យកម្ពុជា នៅពេលដែលការបណ្តុះបណ្តាលទាំងនោះបានរៀបចំឡើងដោយអ្នកផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានកេរ្តិ៍ឈ្មោះ និងរួមបញ្ចូលការវាយតម្លៃជាឯកសារ។

គណៈទន្តពេទ្យកម្ពុជា នឹងបង្កើតបញ្ជីសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត នៃការបណ្តុះបណ្តាលតាមប្រព័ន្ធព័ត៌មានវិទ្យា(Online training) ជាបន្តបន្ទាប់ទាំងក្នុងប្រទេស និងអន្តរជាតិដែល គណៈទន្តពេទ្យកម្ពុជាទទួលស្គាល់។

**សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានលក្ខណៈអន្តរវិជ្ជាជីវៈ**

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានលក្ខណៈអន្តរវិជ្ជាជីវៈ គឺសកម្មភាពទាំងឡាយណាដែល ពាក់ព័ន្ធនឹងវិជ្ជាជីវៈសុខាភិបាលពីរ ឬច្រើន រួមមាន៖

- ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង
- ជំងឺឆ្លង
- ជំងឺមិនឆ្លង
- ការស្រាវជ្រាវពាក់ព័ន្ធនឹងសុខាភិបាល
- សុខភាពបន្តពូជ
- សុខភាពមាតា និងទារក
- បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ (ICT)
- សុវត្ថិភាព និងសុខភាពការងារ
- ការគ្រប់គ្រងគ្រោះមហន្តរាយ
- ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ
- ការគ្រប់គ្រងគុណភាពសេវាសុខាភិបាល
- ការរៀន និងការបង្រៀន

ការបែងចែកពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត សម្រាប់រាល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានលក្ខណៈអន្តរវិជ្ជាជីវៈ នឹងត្រូវបានកំណត់ដោយគណៈទន្តពេទ្យកម្ពុជា។

**៥. សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ចាំបាច់ ដែលគណៈទន្តពេទ្យកម្ពុជាបានកំណត់៖**

គណៈទន្តពេទ្យកម្ពុជា អាចកំណត់សកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលចាំបាច់ ប្រសិនបើសកម្មភាពទាំងនោះត្រូវបានចាត់ទុកថាជាប្រយោជន៍សាធារណៈ ហើយមានគោលដៅជានាគុណភាព និងសុវត្ថិភាព ដល់អ្នកជំងឺ អតិថិជន និងសហគមន៍។

គណៈទន្តពេទ្យកម្ពុជា នឹងចុះផ្សាយនូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តចាំបាច់ដែលបានកំណត់ខាងលើ តាមរយៈគេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀតរបស់គណៈទន្តពេទ្យ និងជូនដំណឹងដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធទាំងអស់។

**៦. តម្រូវការបន្ថែមនានាដែល អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ត្រូវមានលក្ខខណ្ឌលើអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ក្នុងការបំពេញនូវចំនួនសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត**

ប្រសិនបើអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល មានលក្ខខណ្ឌលើអាជ្ញាបណ្ណក្នុងការប្រកបវិជ្ជាជីវៈ ធ្វើការបំពេញសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត នោះគណៈវិជ្ជាជីវៈ នឹងតម្រូវឱ្យពួកគេអនុវត្ត ការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះបន្ថែមលើតម្រូវការ ៦០(ហុកសិប)ពិន្ទុក្នុងវដ្តនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ៣(បី)ឆ្នាំ។

**៧. ការជ្រើសរើសសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត**

រាល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវការឯកសារយោងជាក់លាក់ពីអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ដែលកំណត់ច្បាស់លាស់៖

(១) គោលបំណងនៃសកម្មភាពនេះ

(២) តម្រូវការរៀនសូត្ររបស់បុគ្គល និងផែនការការអភិវឌ្ឍវិជ្ជាជីវៈបន្តផ្ទាល់ខ្លួន

(៣) សកម្មភាពដែលបានចូលរួម

(៤) ពេលវេលាដែលអ្នកបានចូលរួម

(៥) ការសង្ខេបខ្លីពីលទ្ធផលនៃការរៀន ។

សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលពាក់ព័ន្ធនឹងវគ្គបណ្តុះបណ្តាលមានរយៈពេលមួយថ្ងៃ ឬលើស ត្រូវមានឯកសារដែលបង្ហាញពីគោលបំណង និងគោលដៅ ជាមួយអ្នកជំនាញ អ្នកសម្របសម្រួល ឬ/និងអ្នកធ្វើបទបង្ហាញ ដោយរួមបញ្ចូលការវាយតម្លៃដែលបង្ហាញពីការអនុវត្តនូវចំណេះដឹង និងជំនាញថ្មីៗ នៅក្នុងការប្រកបវិជ្ជាជីវៈនេះ ។

គណៈទន្តពេទ្យកម្ពុជា ទទួលស្គាល់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាល សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានរយៈពេលមួយថ្ងៃ ឬលើស រួមមាន៖

- ក្រសួងសុខាភិបាល (MoH)
- សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល
- សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ: បាត់ដំបង ស្ទឹងត្រែង កំពង់ចាម និងកំពត
- វិទ្យាស្ថានជាតិសុខភាពសាធារណៈ
- វិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយុទ្ធពលខេមរភូមិន្ទ
- សាកលវិទ្យាល័យ ឯកជនដែលផ្តល់ការអប់រំផ្នែកសុខាភិបាល-ហើយត្រូវបានអនុញ្ញាតដោយក្រសួងអប់រំយុវជននិងកីឡា (MOEYS) និងក្រសួងសុខាភិបាល
- មន្ទីរពេទ្យរដ្ឋ និងឯកជន
- មន្ទីរសុខាភិបាលខេត្ត

- មន្ទីរពេទ្យបង្អែកខេត្ត
- សមាគមវិជ្ជាជីវៈសុខាភិបាល

ប្រសិនបើអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត មិនមាននៅក្នុងការ បរិយាយខាងលើ ពួកគេត្រូវតែធ្វើការជាដៃគូជាមួយអង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈវិជ្ជាជីវៈទទួលស្គាល់ ឬធ្វើការស្នើសុំទៅគណៈទន្តពេទ្យកម្ពុជា ដើម្បីទទួលស្គាល់ថា ជាអ្នកផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

គណៈវិជ្ជាជីវៈ នឹងមិនទទួលស្គាល់នូវរាល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលបានរៀបចំឡើងដោយក្រុមហ៊ុនឱសថ ឬក្រុមហ៊ុនពាណិជ្ជកម្មតែឯងឡើយ។

***អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តទាំងអស់ ត្រូវតែផ្តល់ឯកសារពាក់ព័ន្ធដែលតម្រូវដោយគណៈវិជ្ជាជីវៈជាមុន ដើម្បីស្នើសុំពិន្ទុនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត។

## ៨. ការរក្សាទុកឯកសារពាក់ព័ន្ធនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត

អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រទទួលខុសត្រូវ និងរក្សាទុកឯកសារពាក់ព័ន្ធដើម្បីជា កស្តុតាងនៃការ–អភិវឌ្ឍវិជ្ជាជីវៈបន្តឱ្យស្របតាមនិយាមវិជ្ជាជីវៈនីមួយៗ ហើយទទួលខុសត្រូវក្នុងការបង្កើតផែនការសិក្សាផ្ទាល់ខ្លួន ដែលកំណត់ពីតម្រូវការសិក្សារបស់សាមីខ្លួន ។

សាមីខ្លួនត្រូវរក្សាកំណត់ត្រានៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត រួមជាមួយនឹងឯកសារយោងណាមួយ សម្រាប់រយៈពេល ៣(បី)ឆ្នាំ ចាប់ពីថ្ងៃដែលអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ បានបញ្ចប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

ការរក្សាកំណត់ត្រានេះ អាចជួយអ្នកប្រកបវិជ្ជាជីវៈ ក្នុងការផ្តល់ព័ត៌មាន ប្រសិនបើមានការស្នើសុំពី គណៈវិជ្ជាជីវៈនៅពេលបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ឬអំឡុងពេលសវនកម្មការអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬអំឡុងពេលស៊ើបអង្កេត ឬសវនកម្មលើពាក្យបណ្តឹងប្រឆាំងនឹងអ្នកប្រកបវិជ្ជាជីវៈ។

គណៈទន្តពេទ្យកម្ពុជា បានបង្កើតផែនការសិក្សាផ្ទាល់ខ្លួនមួយ (សូមមើលឯកសារភ្ជាប់ ក) ដែលជាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តសម្រាប់រយៈពេល ៣(បី)ឆ្នាំ នៃវដ្ត(សូមមើលឯកសារភ្ជាប់ ខ) និងកំណត់ត្រាសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តតែមួយ (សូមមើលឯកសារភ្ជាប់ គ) ដែលអាចត្រូវបានប្រើ ដើម្បីជួយរៀបចំផែនការ និងកត់ត្រាសកម្មភាព ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។ អ្នកមិនចាំបាច់ប្រើឯកសារទាំងអស់នោះទេ ប៉ុន្តែកំណត់ត្រាការអភិវឌ្ឍវិជ្ជាជីវៈបន្ត ត្រូវតែបញ្ចូលព័ត៌មានទាំងអស់ដែលមាននៅក្នុងបញ្ជីកត់ត្រាសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

កស្តុតាងនៃឯកសារយោងរួមមាន៖

- ឈ្មោះ មុខតំណែង និងហត្ថលេខា របស់អ្នកគ្រប់គ្រង ឬអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាលខ្លីៗ(រយៈពេលពី ១ ទៅ ៦ ម៉ោង) នៅក្នុងកន្លែងការងារ ។
- កម្មវិធី ឬវគ្គសិក្សាលើសពីមួយថ្ងៃដែលមានគោលបំណង និងគោលដៅសិក្សាមាតិកាច្បាស់លាស់ ឈ្មោះ និងគុណវុឌ្ឍិរបស់អ្នកធ្វើបទបង្ហាញដែលមានបទពិសោធន៍ដែលផ្តល់ដោយអង្គភាព ឬដៃគូផ្តល់ការ បណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈទន្តពេទ្យទទួលស្គាល់។
- វិញ្ញាបនបត្រនៃការចូលរួម ឬសម្រេចបាន

  លទ្ធផលនៃការវាយតម្លៃណាមួយដែលបានធ្វើ
- កំណត់ត្រាសង្ខេបពីសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្តដោយខ្លួនឯង ដូចជា ការអានឯកសារវិទ្យាសាស្ត្រ ករណីសិក្សា ឬអត្ថបទទិនានុប្បវត្តិ ។

## ៩.អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈទន្តពេទ្យកម្ពុជាទទួលស្គាល់៖

ជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយ ដែលត្រូវបានទទួលស្គាល់ដោយគណៈទន្តពេទ្យ ថាបានបំពេញតាមនិយាម ដែលតម្រូវសម្រាប់ការផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត មានគុណភាពដល់អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ។ អង្គភាព និងដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈទន្តពេទ្យកម្ពុជាទទួលស្គាល់អាចផ្តល់នូវសកម្មវិជ្ជាជីវៈជាក់លាក់ ឬអន្តរវិជ្ជាជីវៈនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬទាំងពីរ ។

ការទទួលខុសត្រូវរបស់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តរួមមាន៖

- មានការទទួលស្គាល់ដោយគណៈទន្តពេទ្យកម្ពុជា ថាជាអ្នកផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- ដើរតួនាទីជាអ្នកផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈបន្ត ត្រឹមត្រូវ និងសមរម្យ ហើយជាដៃគូរបស់អ្នកផ្តល់ការបណ្តុះបណ្តាល ដែលមិនបានទទួលស្គាល់ដោយគណៈទន្តពេទ្យកម្ពុជា
- ប្រកាន់ខ្ជាប់តាមលក្ខណៈវិនិច្ឆ័យទទួលស្គាល់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- ស្វែងរកការគាំទ្រសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- បង្កើតសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលបំពេញតាមនិយាមរបស់គណៈវិជ្ជាជីវៈសម្រាប់ការផ្តល់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត
- ផ្តល់ និងវាយតម្លៃមាតិកានៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត
- បង្កើត ឬស្វែងរកធនធានបង្រៀនដែលពាក់ព័ន្ធ
- ផ្សព្វផ្សាយ និងផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាព
- សហការជាមួយអាជ្ញាធរពាក់ព័ន្ធនៅថ្នាក់ជាតិ ភូមិភាគ និងរាជធានី ខេត្ត
- ទំនាក់ទំនងជាមួយគណៈវិជ្ជាជីវៈ និងអ្នកពាក់ព័ន្ធផ្សេងៗ ដើម្បីធ្វើការវាយតម្លៃលើតម្រូវការរបស់ការបណ្តុះបណ្តាល
- ចូលរួមក្នុងវេទិកាអ្នកផ្តល់ការបណ្តុះបណ្តលការអភិវឌ្ឍវិជ្ជាជីវៈបន្ត
- កាត់បន្ថយទំនាស់ផលប្រយោជន៍ឱ្យនៅទាបបំផុតដែលទាក់ទងនឹងអ្នកគាំទ្រពាណិជ្ជកម្ម និងបង្ហាញពីទំនាស់ផលប្រយោជន៍ណាមួយប្រសិនបើមាន ។

គោលការណ៍ណែនាំជាច់ដោយឡែកមួយ សម្រាប់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ណែនាំអំពីតួនាទីរបស់អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈបន្ត និងការទទួលស្គាល់ និងសកម្មភាពនៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដើម្បីជាជំនួយដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ទាំងអស់បំពេញយ៉ាងពេញលេញ នូវលក្ខខណ្ឌតម្រូវអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដើម្បីបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈរបស់ពួកគេ ។

## ១០. គោលការណ៍បន្ថែមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត

ដោយអនុលោមតាមគោលការណ៍សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ទាំងអស់ត្រូវស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈយ៉ាងតិច ៣(បី)ខែ មុនពេលអាជ្ញាបណ្ណអស់សុពលភាព។ នៅពេលស្នើសុំបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ អ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ត្រូវប្រកាស និងផ្តល់ឯកសារភស្តុតាង ដែលបង្ហាញថាសាមីខ្លួនបានអនុវត្តតាមនិយាមអប្បបរមានៃការអភិវឌ្ឍវិជ្ជាជីវៈបន្ត ។

ក្នុងករណីដែលអ្នកប្រកបវិជ្ជាជីវៈទន្តសាស្ត្រ មិនបានបំពេញពិន្ទុគ្រប់ចំនួនតាមលក្ខខណ្ឌ គណៈទន្តពេទ្យកម្ពុជានឹងមិនបន្តអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈជូនឡើយ។

ការអនុលោមតាមនិយាម និងគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត **គណៈទន្តពេទ្យកម្ពុជា** អាចធ្វើសវនកម្មបានគ្រប់ពេល ឬនៅពេលទទួលបានបណ្តឹងដែលពាក់ព័ន្ធនឹងសម្បទា ឬកំហុសឆ្គងក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ។

***គោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តនេះ ត្រូវបានបង្កើតឡើងដោយគណៈទន្តពេទ្យកម្ពុជា ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល និងនិយាមសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តរបស់គណៈវិជ្ជាជីវៈសុខាភិបាល។

**វាក្យសព្ទ**

**ការអភិវឌ្ឍវិជ្ជាជីវៈបន្ត** សំដៅដល់ដំណើរការនៃការសិក្សាពេញមួយជីវិត ដែលមានគោលបំណងរក្សា និងលើកកម្ពស់នូវការអនុវត្តន៍របស់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល ក្នុងការពង្រីកសមត្ថភាពវិជ្ជាជីវៈ តាមរយៈការសិក្សាស្រាវជ្រាវជំនាញវិជ្ជាជីវៈ សន្និសីទ សិក្ខាសាលា ។ល។ ដើម្បីអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈ។

**ការប្រកបវិជ្ជាជីវៈ** សំដៅដល់រាល់តួនាទីដែលបុគ្គលម្នាក់ៗប្រើជំនាញ និងចំណេះដឹងជាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលក្នុងវិជ្ជាជីវៈរបស់ពួកគេ។ ការប្រកបវិជ្ជាជីវៈ មិនសំដៅតែការផ្តល់សេវាព្យាបាល ថែទាំ វេជ្ជសាស្ត្រ ជាមួយអតិថិជនដោយផ្ទាល់នោះទេ ដោយរាប់បញ្ចូលទាំងការងារគ្រប់គ្រងរដ្ឋបាល អប់រំ/បណ្តុះបណ្តាល សិក្សាស្រាវជ្រាវ ផ្តល់ប្រឹក្សាអភិវឌ្ឍគោលនយោបាយ ឬបទប្បញ្ញត្តិ និងតួនាទីផ្សេងៗទៀត ដែលប៉ះពាល់ដល់សុវត្ថិភាព ប្រសិទ្ធភាពនៃការផ្តល់សេវា តាមរយៈវិជ្ជាជីវៈនោះ ទោះជាបាន ឬមិនបានទទួលកម្រៃក៏ដោយ ។

**អ្នកវិជ្ជាជីវៈសុខាភិបាល** សំដៅដល់គ្រូពេទ្យ ទន្តពេទ្យ ឆ្មប គិលានុបដ្ឋាក ទន្តគិលានុបដ្ឋាក ឱសថការី ដែលទទួលបានការចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈសុខាភិបាលពាក់ព័ន្ធ។

**អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល** សំដៅដល់អ្នកវិជ្ជាជីវៈសុខាភិបាលដែលទទួលបានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ។

**អង្គភាព ឬដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្តដែលគណៈវិជ្ជាជីវៈទទួលស្គាល់** គឺជាអង្គភាព ឬដៃគូជារូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលត្រូវបានទទួលស្គាល់ដោយក្រុមប្រឹក្សាវិជ្ជាជីវៈ ថាបានបំពេញតាមបទដ្ឋានតម្រូវសម្រាប់ការផ្តល់នូវសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលមានគុណភាពដល់អ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។ អង្គភាព និងដៃគូផ្តល់ការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈបន្ត ដែលគណៈវិជ្ជាជីវៈទទួលស្គាល់ អាចផ្តល់នូវសកម្មភាពវិជ្ជាជីវៈជាក់លាក់ ឬអន្តរវិជ្ជាជីវៈនៃសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈបន្ត ឬទាំងពីរ។

គោលការណ៍ណែនាំនេះ នឹងត្រូវពិនិត្យឡើងវិញដោយគណៈទន្តពេទ្យកម្ពុជាតាមការចាំបាច់ ។

**ជ.ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ**

**ប្រធាន**

DENTAL COUNCIL OF CAMBODIA

**ទន្តបណ្ឌិត.សុខុម រិទ្ធិរ៉ុង**